# គ្រូបង្រៀនផ្នែកចុងភៅ

តើអ្នកមានចំណាប់អារម្មណ៍ក្នុងការបណ្តុះបណ្តាលជំនាញផ្នែកចុងភៅដែរឬទេ? តើអ្នកចាប់អារម្មណ៍ធ្វើការដើម្បីធានាឲ្យសហគមន៍ដែលងាយរងគ្រោះ ពិសេសយុវវ័យមានឱកាសទទួលបានជំនាញ និងការងារដែរឬទេ? បើអ្នកចាប់អារម្មណ៍ អ្នកអាចចូលរួមជាមួយយើង!

អង្គការមិត្តសំឡាញ់ គឺជាអង្គការក្នុងស្រុកឈានមុខគេមួយដែលធ្វើការជាមួយកុមារ យុវវ័យ គ្រួសារ ដែលបាត់បងឱកាស និងសហគមន៍របស់ពួកគេ ដើម្បីជួយពួកគេឲ្យក្លាយទៅជាពលរដ្ឋឯករាជ្យ និងមានផលិតភាពសម្រាប់ប្រទេសរបស់ពួកគេ។

ក្រុមពហុជំនាញរបស់យើង រួមមានគ្រូបង្រៀន បុគ្គលិកសង្គម មន្ត្រីដាក់ការងារ អ្នកថែរក្សាកុមារ បាននឹងកំពុងធ្វើការជាមួយគ្នា ដើម្បីធានាថាយើងសង្គ្រោះជីវិត និងកសាងអនាគតឲ្យកុមារ យុវវ័យ គ្រួសារ និងសហគមន៍របស់ពួកគេ។

**តើអ្នកនឹងត្រូវធ្វើអ្វី?**
ក្នុងតួនាទី ជាគ្រូបង្រៀនផ្នែកចុងភៅ អ្នកនឹងក្លាយជាផ្នែកមួយនៃក្រុមការងារនេះ ដើម្បីបង្រៀនជំនាញចុងភៅដល់យុវវ័យ ឲ្យទទួលបាននូវជំនាញច្បាស់លាស់ ដែលអាចទៅបម្រើការងារតាមភោជនីយដ្ឋាន ឬស្ថាប័នផ្សេងៗបាន ។

**តួនាទី នឹងការទទួលខុសត្រូវរបស់គ្រូបង្រៀនផ្នែកចុងភៅមានដូចខាងក្រោម៖**

- ត្រួតពិនិត្យ និងគ្រប់គ្រង ដំណើរការក្នុងផ្ទះបាយ
- ធានាថាផ្ទះបាយ និងបរិវេណស្អាត និងរៀបចំបានត្រឹមត្រូវទៅតាមស្តង់ដារដែលបានកំណត់
- ជំនាញផ្តល់ការបណ្តុះបណ្តាលជំនាញចំអិនម្ហូប ទៅដល់សិស្សទៅតាមស្តង់ដារដែលបានកំណត់
- ធ្វើការតាមដាន និងត្រួតពិនិត្យការងារប្រចាំថ្ងៃរបស់សិស្ស
- ចំណេះដឹងផ្នែកចម្អិនអាហារនៅក្នុងគ្រប់គ្រងភោជនីយដ្ឋាន និងហាងអាហារ

**ល័ក្ខខ័ណ្ឌជ្រើសរើស:**

- អ្នកមានបទពិសោធន៍ ០២ឆ្នាំពាក់ព័ន្ធនឹងការចម្អិនអាហារ
- អ្នកចូលចិត្តធ្វើការងារជាមួយកុមារ/យុវវ័យ និងគ្រួសារ និង ការងារសង្គម
- អ្នកមានមានជំនាញក្នុងការទំនាក់ទំនង អាចធ្វើការងារជាក្រុម មានភាពអត់ធ្មត់ ចេះបត់បែន

បេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ សូមផ្ញើនូវប្រវត្តិរូបសង្ខេប (CV និង Cover Letter) មកទីស្នាក់ការអង្គការមិត្តសំឡាញ់ អាសយដ្ឋានផ្ទះលេខ២១៥ ផ្លូវលេខ១៣ ខាងជើងសារៈមន្ទីរជាតិ ឬ E-mail: hr@mithsamlanh.org ដោយបញ្ជាក់ពីតួនាទី និងប្រាក់បៀវត្សរ៍រំពឹងទុក។ ព័ត៌មានបន្ថែមអាចទំនាក់ទំនងបានតាមរយៈទូរស័ព្ទ ០២៣ ២២០ ៥៩៦។

អង្គការមិត្តសំឡាញ់ ផ្តល់នូវភាពយុត្តិធម៌ដល់អ្នកដាក់ពាក្យទាំងអស់។ បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវទំនាក់ទំនងដើម្បីធ្វើការសម្ភាសន៍។

**អង្គការមិត្តសំឡាញ់គោរពតាមគោលការណ៍ការពារកុមារ។**
**ទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២២។**